# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ២៣ ខែកុម្ភៈ លេខ ២

ព. ស. ២៤៩៣ — គ. ស. ១៩៥១

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងអក្សរសាស្ត្រ និងសាសនា

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកអក្សរសាស្ត្រ | បញ្ជីរឿង | ទំព័រ |
|---|---|---|
| ការបណ្ដុះនិស្ស័យ .......... | ព្រះមហា ប៉ុង ប៉ម ..... | ៨៣ |
| សត្វបារាំងប្រែជាខ្មែរ (តមក) ........ | លោក ម៉ុញ - ទាត្រី ..... | ៩១ |
| រឿងព្រេងភូមា (តមក) .......... | — សាង - សាភ័ត ..... | ៩៥ |
| រឿងសាមកុក (តមក) .......... | — ទួ - កន ........ | ១០៣ |
| ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក) .. | — ឈឹម - ក្រសេម ..... | ១១២ |

**ផ្នែកសាសនា**

| | | |
|---|---|---|
| ពុទ្ធសាសនានិងត្រឹស្តសាសនា (សន្និសីទ លោកវេជ្ជបណ្ឌិតមីតួត) ....... | លោក ភ័យ - ប៊ុក ....... | ១១៨ |
| ពន្លឺអាស៊ីទ្វីប (តមក) ......... | លោក ភ័យ - ប៊ុក ...... | ១២២ |
| ទិដ្ឋធម្មិកត្ថកថា .......... | ព្រះទេពសត្ថា ស្វរ - ហាយ .... | ១២៦ |

**កំណត់និងប្រវត្តិការណ៍**

| | | |
|---|---|---|
| ពិធីទទួលសម្ដេចសង្ឃនាយក ជួន - ណាត នៅវត្តដំណាក់ (សៀមរាប) (តចប់) | ព្រះមហាកែ - អឿន ....... | ១៣៨ |
| អនុសំវច្ឆរៈមហាសន្និបាត .......... | ពុទ្ធសាសនបណ្ឌិត្យ ....... | ១៤១ |



មួយឆ្នាំមាន ១២ សៀវភៅ តំលៃជាវ .............. ១៤៥៛,០០

ទិដ្ឋធម្មិកត្ថកថា

# ព្រះទេពសត្ថា សួរ-ហាយ ក្រុមជំនុំព្រះត្រៃបិដក

**ទេសនាផាក់វិទ្យុនៅថ្ងៃ ៨ កើតខែស្រាពណ៍ ព. ស. ២៤៩១ - ៨ - ១៩៤៨**

នមត្ថុរតនត្តយស្ស

អស់លោកអ្នកស្ដាប់ទាំងឡាយ !

ពេលនេះជាមង្គលមួយដ៏ប្រសើរ ដែលអាត្មាភាពត្រូវនាំមកសំ-ដែងធម៌អំពីប្រយោជន៍បច្ចុប្បន្ន ដើម្បីជាសណ្ដាប់នៃអស់លោក-អ្នកទាំងឡាយដូចសេចក្ដីដែលត្រូវសំដែង ព្រមទាំងអធិប្បាយតទៅនេះ:

## ប្រយោជន៍បច្ចុប្បន្ននេះមាន ៤ យ៉ាង

១ – ឧដ្ឋានសម្បទា = ការគ្រប់គ្រាន់ដោយការក្រោកឡើង

២ – អារក្ខសម្បទា = ការគ្រប់គ្រាន់ដោយការរក្សាថែទាំ

៣ – កល្យាណមិត្តតា = ភាពនៃបុគ្គលជាអ្នកមានមិត្តល្អ

៤ – សមជីវិតា = ភាពនៃបុគ្គលជាអ្នកមានការចិញ្ចឹមជីវិតសមគួរ ។

## អធិប្បាយប្រយោជន៍ទី ១

ការបរិបូណ៌ដោយហេតុដែលគួរប្រកប ដើម្បីឲ្យបានសម្រេចដូចបំណង ហៅថា សម្បទា ។ សម្បទានេះ ប្រែថា "គ្រប់គ្រាន់, ជាគុណជាតិជាគ្រឿងផ្ដល់ ឬជាគ្រឿងប្រគល់ឲ្យនូវប្រយោជន៍" ។

ឧដ្ឋានសម្បទា ដែលថា "ការគ្រប់គ្រាន់ដោយការក្រោកឡើង" នោះតើក្រោកឡើងប្រកបការងារដូចម្តេច? ការងាររបស់មនុស្ស ដែលត្រូវប្រកបក្នុងលោកនេះ មានច្រើនយ៉ាងគឺការងារខ្លះធ្ងន់, ខ្លះស្រាល, ខ្លះធំ, ខ្លះតូច; ការងារខ្លះជាប្រយោជន៍ផ្ទាល់ខ្លួន, ខ្លះជាប្រយោជន៍សាធារណ; ការងារខ្លះប្រកបដោយទោស, ខ្លះប្រាសចាកទោស; ការងារខ្លះបានផលច្រើន, ខ្លះបានផលតិច តាមគ្រាន់ហេតុរបស់ការងារនោះៗ ។

បណ្តាការងារទាំងអស់ក្នុងលោកនេះ, ការងារណាក៏ដោយ តាំងអំពីការសិក្សារៀនសូត្រ ធ្វើស្រែចំការជួញប្រែជាដើមនោះ សុទ្ធតែត្រូវប្រកបដោយឧដ្ឋានៈ គឺការក្រោកឡើងមមីមមាររៀសរវៃ ប្រញាប់ចាប់កិច្ចការដែលខ្លួនត្រូវធ្វើដោយម៉ត់ចត់ទាំងអស់ ទើបសម្រេចផលដូចបំណងទៅបាន, បើមិនច្រើនក៏តិចតាមកំឡាំងនៃការងារនិងកំឡាំងនៃសេចក្តីព្យាយាម ។

ការងារទាំងឡាយដែលត្រូវប្រកបចុះដៃធ្វើនោះ ច្រើនតែមានហេតុចង្រៃមកកាំងខ្ទាំងខ្ទាស់ឬដែលហៅថាមារដ្រែក បាលីហៅថាឧបសគ្គ ។ បើការងារតូចបោកទាប មានឧបសគ្គបន្តិចបន្តួច, បើការងារធំខ្ពង់ខ្ពស់ មានឧបសគ្គក៏ច្រើន; ឧបសគ្គនេះតែងតាមប្រណាំងប្រជែងបៀតបៀនការងារទាំងអស់ធម្មតា ។ សេចក្តីព្យាយាមក្នុងការងារដែលចេះតែក្លាយចេះតែខកខាន ក៏ព្រោះឧបសគ្គនេះឯង ។

សេចក្ដីប្រឹងប្រែងខ្មីឃ្មាតក្រោកឡើងម្នីម្នានេះ តាមបាលីហៅថា ឧដ្ឋានៈ; ពាក្យថា ឧដ្ឋានៈនេះ ជាឈ្មោះនៃសេចក្ដីព្យាយាមដែលមានកំឡាំងក្លៀវក្លា ។

ពាក្យថា ព្យាយាមនេះ ខ្មែរយើង មានពាក្យវេវចនស័ព្ទ គឺសំដីដែលនិយាយផ្លាស់ប្ដូរជាច្រើនយ៉ាង, ភាសាបាលីក៏មានវេវចនស័ព្ទច្រើនយ៉ាងដែរ ។ ដូចឧដ្ឋានៈ = ការក្រោកឡើង, វីរិយៈ = ប្រាសចាកសេចក្ដីរញ្ញក, វាយាមៈ = ព្យាយាមប្ដូរឈានទៅមុខ, ឧស្សាហៈ = ខ្មីឃ្មាត, បរក្កមៈ = ទទូច, អដ្ឋិតិ = មិនឈប់នៅ, អប្បដិវានី = មិនត្រឡប់ថយក្រោយ, អនិក្ខិត្តឆន្ទតា = មិនបោះបង់សេចក្ដីប្រាថ្នា, អសិថិលបរក្កមតា = ទំប្រឹងប្រែងមិនបន្ធូរបន្ថយ, អនិក្ខិត្តធុរតា = មិនដាក់ធុរៈចោល ។

សេចក្ដីខ្នះខ្នែងក្រវើនក្រវ៉ើនក្នុងកិច្ចការ មិនបណ្ដែតបណ្ដោយមិនធ្វេសប្រហែសពាយឆាយ, មិនខ្ជីខ្ជា គឺមានភាពជាអ្នកស្រក់ស្រទេញ ស្រឡាញ់ការងារដែលខ្លួនត្រូវធ្វើ, មិនខ្លាចលំបាក. មិនគិតពីការហត់នឿយ, ទំប្រឹងកំចាត់នូវកោសជ្ជៈសេចក្ដីខ្ជិលច្រអូសចេញចាកខន្ធសន្តាន; ព្រោះថាកោសជ្ជៈនេះជាទំនាស់គ្នានឹងសេចក្ដីព្យាយាម; ទោះបីមានឧបសគ្គយ៉ាងណា ក៏មិនត្រូវទំលាក់ការដែលខ្លួនធ្វើនោះចោលឡើយ ។

ឧបស័គ្គ សេចក្តីចង្រៃខ្លាំងខ្លប់ ទាំងសាបរលាបរលាយបាត់ទៅ ក៏ព្រោះសេចក្តីព្យាយាម ។ បុគ្គលអ្នកមានសេចក្តីព្យាយាមប្រឹងប្រែង ទុកដូចជាអ្នកមានថ្នាំឧសថវិសេស សម្រាប់បន្សាបនូវពិសកាច គឺ ឧបស័គ្គ ទាំងកោសជ្ជៈឲ្យស្ងប់រម្ងាប់ ។ បុគ្គលអ្នកមានព្យាយាម រមែងចំរើន ចំរុងចំរើនដោយទ្រព្យធនធានយសបរិវារ ប្រសើរលើសជាងបុគ្គលអ្នកខ្ជិល ច្រអូសដោយពិត ។

ព្រះសម្ពុទ្ធជាម្ចាស់ ដែលទ្រង់បានសម្រេចសម្មាសម្ពោធិញ្ញាណ ត្រាស់ដឹងឡើង ព្រោះតែសេចក្តីព្យាយាមនេះឯង ។ សេចក្តីព្យាយាមនេះ ជាបារមី ១ ដ៏ប្រសើររបស់ព្រះពោធិសត្វ ដែលកំពុងកសាងនៅឡើយ ហៅថា វិរិយបារមី ។ មួយទៀតការព្យាយាមមិនរួញរានេះ ជាកំឡាំង មួយធំបំផុត ហៅថា វិរិយពលៈ ។

ព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់ដឹងហើយ ឧស្សាហ៍ប្រោសប្រទាន ធម៌ទេសនាអំពីសេចក្តីព្យាយាមនេះជាញឹកញយណាស់ ចំពោះពុទ្ធបរិសទ្យទាំងគ្រហស្ថនិងបព្វជិត ដាស់តឿនមិនឲ្យខ្ជិលច្រអូសដំអក់ទំនេរក្នុង កិច្ចការដែលខ្លួនត្រូវធ្វើ ដើម្បីឲ្យបានចំរើនប្រយោជន៍ក្នុងបច្ចុប្បន្ន ។

សេចក្តីព្យាយាមនេះឈ្មោះថាជាឥដ្ឋារម្មណ៍ គឺ អារម្មណ៍ជាទីប្រាថ្នា ជាទីស្រឡាញ់របស់អ្នកប្រាជ្ញគ្រប់សម័យ ។ ចំណែកខាងកោសជ្ជៈ សេចក្តីខ្ជិលច្រអូសឈ្មោះថាជាអនិដ្ឋារម្មណ៍ គឺអារម្មណ៍មិនជាទីប្រាថ្នា

មិនដាច់ស្រឡាញ់របស់អ្នកប្រាជ្ញទាំងឡាយ តាំងពីកាលណាមក ។ សាសនធម៌ គឺពាក្យប្រៀនប្រដៅរបស់អ្នកប្រាជ្ញក្នុងលោកមានព្រះពុទ្ធជាដើម តែងមានការសរសើរសេចក្តីព្យាយាមនេះរឿយៗណាស់ ។

អ្នកប្រាជ្ញទាំងអស់ក្នុងលោកមិនរើសថា អ្នកប្រាជ្ញក្នុងសាសនាណាទេ សុទ្ធតែស្រឡាញ់សេចក្តីព្យាយាម ស្អប់សេចក្តីខ្ជិល, សូម្បីគ្រូអាចារ្យមាតាបិតារបស់យើង ក៏ស្រឡាញ់អ្នកមានព្យាយាម ស្អប់មនុស្សខ្ជិលដែរ ។ ព្រោះថាសេចក្តីព្យាយាមនេះ ជាគុណនាំឲ្យភ្ញាក់ដឹងខ្លួនទាន់កាលសម័យ ហើយអាចឈោងចាប់យកប្រយោជន៍បានភ្លាមៗ គឺនាំឲ្យចំរើនភោគសម្បទ, វិជ្ជាសម្បត្តិ ទឹងបរិក់សម្បត្តិ, ចំណែកឯការសេចក្តីខ្ជិលច្រអូសជាទោសមួយធំបំផុត ដែលនាំឲ្យប្រទេសជាតិអាប់ឱនលិចលង់ ឲ្យល្ងង់ទៅ ឲ្យឃ្លាតចាកប្រយោជន៍ដែលគួរបានតាមកាលសម័យ គឺនាំឲ្យវិនាស ក្រខ្សត់ខ្សោយ ថោកទាបរហេមរហាមជាដរាបក្នុងបច្ចុប្បន្ននេះ ។ បុរសស្ត្រីអ្នកមានព្យាយាម តែងបាននូវលាភយសពេញជាក់ច្បាស់ក្នុងបច្ចុប្បន្ន ទោះបីបុគ្គលមិនសូវមានបុណ្យព្រេងអំពីជាតិមុនច្រើនក៏ដោយ តែបើជាអ្នកប្រកបដោយសេចក្តីព្យាយាមជាប់ល្អហើយ ទៀងតែងនឹងបានឋានន្តរទីដំណែងដ៏ប្រសើរ បើមិនបានធំក៏គួរមិនខាន ។ បុគ្គលអ្នកមានព្យាយាមត្រូវទទួលផលប្រយោជន៍ ឥតមានទោសទាស់នឹងច្បាប់ពុទ្ធសាសនាឡើយ ។

សេចក្ដីព្យាយាមនេះ មានអានិសង្សឲ្យឃើញជាក់លាក់ក្នុងលោក ទុកដូចជាស្នេហ៍មុខមួយសម្រាប់ប្រគល់ឲ្យនូវគុណគឺ លាភយសសរសើរ សុខ ដល់បុរសស្ត្រីអ្នកមានព្យាយាមនោះវិញ ។ សមដូចពុទ្ធភាសិតថា **បដិរូបការី ធុរវាឧដ្ឋាតា វិន្ទតេ ធនំ** បុគ្គលអ្នកមានធុរៈទទួលការការប្រឹងប្រែងរមែងបាននូវទ្រព្យសម្បត្តិ, **វីរិយេន ទុក្ខមច្ចេតិ** បុគ្គលកន្លងនូវទុក្ខព្រួយបានក៏ព្រោះព្យាយាម, **វាយមេថេវ បុរិសោ យាវ អត្ថស្ស និប្ផទា** បុគ្គលជាកូនប្រុសគួរប្រឹងប្រែង កុំលែងឲ្យទាល់តែសម្រេចប្រយោជន៍, **ទឡ្ហមេតំ បរក្កមេ** ត្រូវប្រឹងប្រែងចំពោះការនោះឲ្យមាំមួន ” ។

បុគ្គលអ្នកមានប្រាថ្នាសេចក្ដីសុខចំរើនរុងរឿង ត្រូវតែមានព្យាយាមឲ្យស្វិតស្វាញក្នុងកិច្ចការទាំងពួង តាមវយៈកាលនៃវ័យទាំង ៣ គឺ បឋមវ័យ ជាកាលត្រូវទទួលធុរៈខាងការសិក្សាអក្សរសាស្ត្រនិងវិទ្យាសាស្ត្រផ្សេងៗ, មជ្ឈិមវ័យ ជាកាលត្រូវស្វែងរកភោគសម្បទ, បច្ឆិមវ័យ ជាកាលត្រូវប្រព្រឹត្តសីលធម៌ ដើម្បីឲ្យសមតាមថ្នាក់ជាមនុស្សចាស់ទុំ ។ សេចក្ដីអធិប្បាយមកនេះហៅថា ឧដ្ឋានសម្បទា ។

## អធិប្បាយប្រយោជន៍ ទី ២

ការគ្រប់គ្រាន់បរិបូណ៌ដោយគំនិតមារយាទ ដែលចេះរក្សាទ្រព្យធនមិនឲ្យវិនាសបង់ដោយអន្តរាយផ្សេងៗ មានអន្តរាយដោយភ្លើងនេះ

ទឹកលិច ចោរលួចជាដើម ។ ការបេះទុកដាក់លាក់រក្សារៀបចំទ្រព្យសម្បត្តិតាំងខាងក្នុងផ្ទះតាំងខាងក្រៅផ្ទះដោយការប្រយ័ត្ន មិនភ្លេចគ្រប់វេលាយប់ថ្ងៃ. នេះជាហេតុ ១ ដ៏ប្រសើរដែលនាំឲ្យគង់ទ្រព្យសម្បត្តិចំរើនដល់ខ្លួនទាំងវង្សត្រកូលរបស់ខ្លួនវែងឆ្ងាយតទៅ ។ បុរសស្ត្រីក្តី ត្រកូលណាមួយ ដែលធ្លាប់បានចំរើនមានសម្បត្តិ ហើយត្រឡប់ទៅជាធ្លាក់ខ្លួនថោកទាបក្រតាល់ទៅវិញនោះ ក៏ព្រោះហេតុតែមិនបរិបូណ៌ដោយការរក្សាថែទាំ ដែលហៅថាធ្វេសប្រហែសភ្លេចស្មារតីឬហៅថាខ្វះអារក្ខសម្បទា ។ ដូចបុគ្គលខ្លះក្នុងលោកនេះ មានទ្រព្យសម្បត្តិត្រឹមតែមួយជីវិតខ្លួនក៏មាន មិនដល់មួយជីវិតក៏មាន, មានទ្រព្យសម្បត្តិជាប់យូរអង្វែងរហូតដល់ច្រើនតំណត្រកូលទៅក៏មាន ។

បុគ្គលដែលមានភោគសម្ប័ទស្តុកស្តម្ភហើយ មិនតាំងនៅយូរបានដោយហេតុ ៤ យ៉ាងគឺ **នដ្ឋំ ន គវេសន្តិ** មិនស្វែងរកទ្រព្យធនដែលវិនាសខូចខាតហើយ ១, **ជិណ្ណំ នប្បដិសង្ខរោន្តិ** មិនជួសជុលអបស្តួបរបស់ដែលចាស់គ្រាំគ្រា ១, **អបរិមិត្តភោជិកា ហោន្តិ** ជាអ្នកប្រើប្រាស់របស់មិនមានកំណត់ប្រមាណ គឺជាបុគ្គលខ្ជះខ្ជាយហួសហេតុ ១, **ទុស្សីលំ ឥត្ថឹ វា បុរិសំ វា អាធិបច្ចេ ឋបេន្តិ** តាំងស្ត្រី ឬបុរសទុស្សីល ទុកក្នុងទីជាអធិបតី គឺជាអ្នកកាន់ការផ្ទះ ១ ។ ត្រកូល

ដែលធ្លាក់ថោកទាបទៀតក្រោយទៅជាក្រទាល់ ដោយហេតុ ៤ ប្រការនេះឯង ៗ ត្រកូលនេះឈ្មោះថាខ្វះអារក្ខសម្បទា ៗ

ចំណែកត្រកូលអ្នកមានភោគសម្ប័ទស្តុកស្តម្ភជាប់យូរអង្វែងច្រើនតំណទៅបាន ក៏ព្រោះតែហេតុ ៤ ប្រការ គឺ **នដ្ឋំ គវេសន្តិ** ស្វែងរកទ្រព្យធនដែលវិនាសខូចខាត ១, **ជិណ្ណំ បដិសង្ខរោន្តិ** ជួសជុលអបស្ករបស់ដែលចាស់គ្រាំគ្រា ១, **បរិមិត្តភោជនា ហោន្តិ** ជាអ្នកប្រើប្រាស់របស់មានកំណត់ប្រមាណមិនខ្ជះខ្ជាយ ១, **សីលវន្តំ ឥត្ថឹ វា បុរិសំ វា អាធិបច្ចេ ឋបេន្តិ** តាំងស្ត្រី ឬ បុរសមានសីលទុកក្នុងទីជាអធិបតី គឺជាអ្នកកាន់ការផ្ទះ ១ ៗ

បុគ្គលដែលប្រកបដោយហេតុ ៤ យ៉ាងនេះ ឈ្មោះថាជាអ្នកប្រកបដោយអារក្ខសម្បទាដ៏គ្រប់គ្រាន់ ៗ

## អធិប្បាយប្រយោជន៍ទី ៣

បុរសស្ត្រីដែលកើតមកក្នុងលោកនេះ ទោះជាបុគ្គលជាន់ខ្ពស់ក្តី ជាន់ទាបក្តី នឹងនៅតាមទំនើងខ្លួនឯងម្នាក់ៗ ពុំបានឡើយ ត្រូវតែមានការសេពគប់រាប់រកទទួលស្គាល់អ្នកដទៃផងជាដរាប ៗ បុគ្គលដែលគេសេពគប់ក៏មានច្រើនពួក គឺជាពួកមនុស្សពាលទុច្ចរិតក៏មាន, មនុស្សកណ្តាលៗ ល្មមសេពគប់បានក៏មាន, មនុស្សជាបណ្ឌិតក៏មាន ៗ ការសេព

គប់នេះជាការសំខាន់បំផុត គឺជាមូលហេតុជាបច្ច័យនាំឲ្យបានទទួលទុក្ខទោសក៏មាន, នាំឲ្យបានសុខចំរើនឡើងក៏មាន, ព្រោះហេតុនោះការសេពគប់នេះ ត្រូវប្រយ័ត្នឲ្យណាស់ បើប្រទះនឹងបុគ្គលពាលហើយគប់គេដោយពេញចិត្ត ចូលគំនិតនឹងបុគ្គលពាល រមែងនាំមកនូវសេចក្ដីវិនាសឃើញជាក់ច្បាស់ក្នុងបច្ចុប្បន្ន ។

ការសេពគប់នឹងបណ្ឌិតដែលជាអ្នកមានសីលធម៌ល្អ រមែងនាំមកនូវសេចក្ដីសុខសួស្ដី ។ ការសេពគប់មនុស្សពាលឈ្មោះថាជាការសេពខុសដែលនាំឲ្យខាត ។ ការសេពគប់បណ្ឌិត ឈ្មោះថាជាការសេពគប់ត្រូវ ដែលនាំផ្លូវឲ្យបានចំណេញ ឲ្យសុខចំរើនឥតគាក់ដោយពិត ។ ការសេពគប់នេះ ជាដើមផ្លូវនៃការខូចខាតនិងការចំរើន ហេតុនោះត្រូវយើងពិនិត្យសង្កេតមើលឲ្យជាក់លាក់ ត្រូវសេពគប់ចំពោះតែមនុស្សដែលមានសីលធម៌ល្អ ជាកល្យាណមិត្រ ទើបសម្រេចប្រយោជន៍ផ្លូវបំណងក្នុងបច្ចុប្បន្ននេះបាន ។

## អធិប្បាយប្រយោជន៍ទី ៤

ការចែលកចែងចំណែកទ្រព្យសម្បត្តិ ទំនុកបំរុងជីវិតឲ្យសមគួរតាមកំឡាំងទ្រព្យសម្បត្តិដែលរកបាន មិនឲ្យខ្ជះខ្ជាយពេក មិនកំណាញ់រឹតត្បិតពេក ដើម្បីឲ្យជាប្រយោជន៍បានសុខទាំងចំណែកខ្លួននឹងអ្នកដទៃ ។ ការចាយក់យខ្ជះខ្ជាយនោះ ជាហេតុឲ្យកើតវិប្បដិសារៈ ក្ដៅ

ក្រហាយស្តាយក្រោយក្នុងកាលដែលខ្លួនអស់ទ្រព្យសម្បត្តិ; ការចាយវាយកំណាញ់ត្បិតត្បៀតហួសហេតុពេកនោះ ក៏ជាហេតុឲ្យមានគរហានិន្ទា ដែលមិនជាទីស្រឡាញ់មេត្រីរាប់អាន នៃពួកជនទាំងខាងក្នុងផ្ទះទាំងខាងក្រៅផ្ទះ ព្រោះហេតុនោះ ការប្រើប្រាស់ទ្រព្យសម្បត្តិដែលប្រកបដោយលក្ខណៈត្រឹមត្រូវជាប្រយោជន៍ប្រសើរ ។

អ្នកមានទ្រព្យសម្បត្តិ ដឹងប្រមាណក្នុងការចាយវាយ ជាហេតុឲ្យកើតសេចក្តីកក់ក្តៅក្នុងចិត្ត, ទ្រព្យសម្បត្តិដែលស្វែងរកបានមកហើយនោះមិនមែនសម្រាប់ចំពោះតែខ្លួនឯងម្នាក់ទេ ត្រូវតែបែងចំណែកទ្រព្យសម្បត្តិចេញជា ៥ ចំណែក គឺ ចាយវាយដើម្បីឲ្យសុខស្រួលដល់ខ្លួនឯងនិងមាតាបិតា បុត្រភរិយារបស់ខ្លួន ១, ដើម្បីឲ្យសុខស្រួលដល់ញាតិមិត្រដែលគួរសង្គ្រោះ ១, សំចៃទ្រព្យសម្បត្តិទុកការពារអន្តរាយ ១, ធ្វើទក្ខិណាទានក្នុងសាសនា ១, ធ្វើពលីទាំង ៥ យ៉ាង មានញាតិពលីជាដើម ១ ។

ការបែងចំណែកទ្រព្យសម្បត្តិត្រូវតាមដំណើរ ៥ យ៉ាងនេះ ហៅថាសមជីវិតា ដែលប្រែថា ការចិញ្ចឹមជីវិតដ៏ល្មមសមគួរ គឺមិនខ្ជះខ្ជាយហួសទ្រព្យសម្បត្តិដែលខ្លួនរកបាន មិនរឹតត្បិតហួសខុសតម្រាពេក ។ បុគ្គលជាគ្រហស្ថប្រុសស្រី អ្នកដែលប្រាថ្នានឹងតាំងខ្លួនឲ្យបានសុខស្រួលធូរទូលាយ ដែលហៅថាជាអ្នកយោងខ្លួនរួចនោះ ត្រូវតែមានការរក្សាខ្លួនទុកឲ្យល្អ វៀរចាកអបាយមុខ ដែលជាផ្លូវនាំឲ្យវិនាសចេញឲ្យ

ស្រឡះ គឺជាអ្នកមិនលេងល្បែងភ្នាល់ ១, មិនផឹកទឹកស្រវឹងគឺ សុរានិង មេរ័យ ១, មិនលោភខ្លាំងក្នុងផ្លូវមាតុគ្រាម ១, មិនសេពគប់មនុស្សពាល យកជាមិត្រ ១ ។

ការចិញ្ចឹមជីវិតសមគួរ ដែលត្រូវតាមលក្ខណៈសម្បត្តិ ដូចពោល មកនេះ ហៅថា សមជីវិតា ។

ព្រះពុទ្ធសាសនា ជាសាសនាប្រាប់ប្រយោជន៍ទាំងផ្លូវបច្ចុប្បន្ន និងបរលោក ដើម្បីឲ្យប្រជាជនទទួលអំណោយសេចក្ដីសុខ ចំរើនសម ដូចសេចក្ដីប្រាថ្នា, មិនមែនពន្យល់បំភ្លឺចំពោះតែប្រយោជន៍ទៅបរលោក តែម្យ៉ាង ឬមិនមែនបណ្ដោយឲ្យដេកចាំព្រេងសំណាងនោះឡើយ ។

ព្រះពុទ្ធសាសនាសម្បូណ៌ពាក្យប្រៀនប្រដៅប្រយោជន៍ក្នុងបច្ចុប្បន្ន-នេះ ឲ្យប្រជាជនសិក្សាប្រតិបត្តិតាមនោះជាច្រើនន័យណាស់ មិនមែន ខ្វះទេ គឺជាពាក្យដំបូន្មានរំលឹកដាស់តឿននេះ មានក្នុងគម្ពីរព្រះពុទ្ធ-សាសនាជាច្រើនណាស់, មិនមែនព្រះពុទ្ធសាសនានាំឲ្យខ្ជិលច្រអូស ឲ្យរង់ចាំផលទៅអនាគតតែម្យ៉ាងនោះឡើយ ។

ពណ៌នាធម្មកថាអំពីប្រយោជន៍បច្ចុប្បន្ន ៤ យ៉ាង ក៏សូមសន្មត បញ្ចប់តែប៉ុណ្ណេះ ។

សូមជូនពរចំពោះអស់លោកអ្នកស្ដាប់ទាំងឡាយ ឲ្យបានប្រកប ដោយឥដ្ឋមនុញ្ញផលគ្រប់ៗ គ្នា ។

ទុក្ខប្បត្តា ប និទ្ទុក្ខា ភយប្បត្តា ប និព្ភយា
សោកប្បត្តា ប និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។

“សព្វសត្វទាំងឡាយ ដែលដល់នូវសេចក្ដីទុក្ខ, សូមឲ្យជាអ្នកផុតទុក្ខទៅ ! ដែលដល់នូវភ័យ, សូមឲ្យជាអ្នកផុតភ័យទៅ ! ដែលដល់នូវសេចក្ដីសោក សូមឲ្យជាអ្នកបាត់សោកទៅ !”

រតនត្តយតេជេន កម្ពោជរដ្ឋវាសិនោ
វឌ្ឍឹ វិរុឡ្ហឹ បប្បោន្តុ សន្តិភាវញ្ច ទាញ្ញហា ។

“ដោយតេជៈនៃព្រះរតនត្រ័យ សូមឲ្យប្រជាជនទាំងឡាយអ្នកនៅកម្ពុជរដ្ឋ ដល់នូវការលូតលាស់ចំរើន និងសន្តិភាព កុំបីឃ្លាតក្លាយទៅជាប្រការៈដទៃឡើយ !” ។